ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ : ៣០៧៤ មស.ក្រស

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
**សូមគោរពជូន**
**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន**

**កម្មវត្ថុ** :-សំណើសុំពន្លឿនការតាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការស៊ីវិល ។

**យោង** :-ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

ខ្ញុំមានកិត្តិយស សូមជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នមេត្តាជ្រាបថា ដើម្បីឱ្យការតាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការស៊ីវិល បានទាន់ពេលវេលា និងជាផលប្រយោជន៍ដល់មន្ត្រីរាជការ ក្រសួងមុខងាសាធារណៈ សូមជម្រាបជូនគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមេត្តាយកចិត្តទុកដាក់អនុវត្តលើការតាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការស៊ីវិលឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់ ដោយចូលរួមសហការអនុវត្ត ដូចតទៅៈ

១-មន្ត្រីរាជការដែលដល់ថ្ងៃ ខែ ឆ្នាំតាំងស៊ប់ក្នុងក្របខ័ណ្ឌក្រសួងស្ថាប័នសាមី ត្រូវធ្វើលិខិតស្នើសុំតាំងស៊ប់មកក្រសួងមុខងារសាធារណៈ ក្រោយពីបានធ្វើកម្មសិក្សាបញ្ចប់ដោយជោគជ័យរួចមក ។

២-ចំពោះមន្ត្រីរាជការដែលបានតាំងស៊ប់ក្នុងក្របខ័ណ្ឌរួចហើយ ក្រសួង ស្ថាប័នសាមី ត្រូវធ្វើលិខិត និងបញ្ជីឈ្មោះមកក្រសួងមុខងារសាធារណៈ ដើម្បីធ្វើបច្ចុប្បន្នភាពនៅក្នុងប្រព័ន្ធទិន្នន័យមន្ត្រីរាជការ ។

សូមជូនភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះមន្ត្រីរាជការដែលមិនទាន់តាំងស៊ប់ក្នុងក្របខ័ណ្ឌ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នមេត្តាជ្រាប និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ពេជ្រ ប៊ុនធិន

**ចម្លងជូន**
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ឯកសារ-កាលប្បវត្តិ